long beach unified school district

OFFICE OF EQUITY, ACCESS, COLLEGE & CAREER READINESS
Volunteers in Public Schools

VIPS make a difference

Parent University

# មធ្យោបាយបំពេញក្រដាសដាក់ពាក្យសុំស្ម័គ្រធ្វើជា VIPS

## ការបំពេញក្រដាស គឺតំរូវធ្វើក្នុងរយៈពេល បួន ឆ្នាំ ម្តង

### មុខងារទទួលខុសត្រូវសំរាប់ VIPS ថ្មី

**បើអ្នកមានបំណងសុំស្ម័គ្រធ្វើជា VIPS គឺសូមធ្វើតាមមធ្យោបាយដូចតទៅ:**

**បំពេញ** ក្រដាសដាក់ពាក្យ VIPS ដែលមានជាភាសា អង់គ្លេស និង ខ្មែរ ។

**ទៅធ្វើ** តែស្ត ស្បែក សំរាប់ពិនិត្យរោគរបេង ដែលផ្តល់ឡើងមិនគិតថ្លៃដោយក្រសួងអប់រំ ឱស្រ្ទីគ ជាមួយវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់អ្នក ឬ នៅតាមក្រសួងណាមួយដែលមានឈ្មោះរាយនៅលើក្រដាសភ្ជាប់មកនេះ ។ ការបញ្ជាក់អំពីរោគ របេង គឺត្រូវបង្ហាញ ថ្ងៃ/ខែ ធ្វើ តែស្ត ស្បែក ថ្ងៃ/ខែ អាន តែស្ត ស្បែក (ចន្លោះពេល 48-72 ម៉ោង) លទ្ធផលពីការធ្វើ តែស្ត ស្បែក និង ឈ្មោះមន្ទីរពេទ្យ ។ អ្វីអាចប្រើជំនួសបាន គឺការឆ្លើយសំនួរនៅលើក្រដាសពិសេសមួយ ហៅ TB Risk Assessment Questionnaire Certificate of Completion ដែលស្ថិតនៅក្រោមការពិនិត្យដោយបុគ្គលិកពេទ្យណាម្នាក់មានសញ្ញាប័ត្រស្របច្បាប់ ។ សំរាប់សំនួរអំពី X-ray គឺសូមទាក់ទងតាមលេខទូរស័ព្ទ (562) 997-8307 ។

បន្ទាប់ទៅ យកក្រដាសបំពេញត្រឹមត្រូវ ក្រដាសចម្លងអំពីប័ណ្ណ ID សំគាល់ខ្លួន ដែលមានរូបថតច្បាស់ និង ក្រដាសបង្ហាញលទ្ធផលអំពីរោគ របេង ទៅប្រគល់ជូនអ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀន ។ អ្វីបំពេញមិនត្រូវ ឬ ខ្វះ គឺនឹងធ្វើឲ្យពន្យារពេល ។ បើអ្នកនឹងសុំស្ម័គ្រជួយនៅតាមសាលារៀនច្រើនកន្លែង គឺអ្នកត្រូវឆ្លើយបំពេញក្រដាសដាក់ពាក្យសំរាប់**សាលារៀននិមួយៗទាំងអស់នោះ** ។

- អ្នកចាត់ចែងកម្មវិធី VIPS នឹងផ្ញើទៅកាន់ការិយាល័យ … Equity, Access, College & Career Readiness (EACCR) នៅទីចាត់ការនៃក្រសួងអប់រំ ឱស្រ្ទីគ អំពីអ្វីដូចតទៅ:
    1. ក្រដាសដាក់ពាក្យបំពេញត្រឹមត្រូវសំរាប់សុំស្ម័គ្រជា VIPS
    2. ក្រដាសបង្ហាញលទ្ធផលអំពីរោគ របេង ឬ ក្រដាសចម្លើយអំពី TB Risk Assessment Questionnaire Certificate of Completion
    3. ក្រដាសចម្លងអំពីប័ណ្ណ ID សំគាល់ខ្លួន ដែលមានរូបថត និង មិនទាន់ហួស ថ្ងៃ/ខែ
- ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឱស្រ្ទីគ នឹងរត់ការក្រដាសស្នាម ដែលបានទទួលពីអ្នក* បញ្ជាក់មើលលទ្ធផលអំពីរោគ របេង របស់អ្នក និង ធ្វើការបញ្ជាក់បន្ថែម ស្របច្បាប់ Megan's Law ។
- បន្ទាប់ទៅ ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឱស្រ្ទីគ នឹងផ្ញើដំណឹងអំពីការទទួលយល់ព្រមទៅកាន់អ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀនវិញ ដោយមានភ្ជាប់ប័ណ្ណ VIPS ID សំរាប់ពាក់ទៅជាមួយផង ។
- អ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀននឹងទាក់ទងប្រាប់អ្នក ហើយអ្នកអាចចាប់ផ្តើមស្ម័គ្រជួយកិច្ចការនៅក្នុងសាលារៀនភ្លាម បន្ទាប់ពីបានចូលរួមស្តាប់ការពន្យល់ពត៌មាន និង បានទទួលសៀវភៅពត៌មានផុតទៅ ។
- ដើម្បីការពារសិស្ស និង រក្សាភាពសន្តិសុខទូទៅនៅតាមសាលារៀន គឺអ្នកត្រូវសរសេរឈ្មោះរៀងរាល់លើក នៅពេលចូលសាលារៀន និង ចេញពីសាលារៀន ។ អ្នកត្រូវពាក់ប័ណ្ណ VIPS ID គ្រប់ពេលវេលា (លើកលែងតែនៅពេលធ្វើដំណើរផ្លូវឆ្ងាយជាមួយសិស្ស) និង មិនត្រូវឲ្យមនុស្សណាផ្សេងខ្ចីពាក់ប័ណ្ណ VIPS ID នោះទេ ។

### ចំពោះអ្នកសុំស្ម័គ្រ VIPS ដែលត្រឡប់ចូលវិញ ធ្លាប់បានធ្វើពីមុនមក ឬ សុំផ្លាស់មកធ្វើពីសាលារៀនផ្សេង

1. **<u>បើអ្នកត្រឡប់សុំស្ម័គ្រជួយនៅតាមសាលារៀនដដែល</u>** គឺអ្នកត្រូវពិគ្រោះជាមួយអ្នកចាត់ចែងកម្មវិធី VIPS នៅសាលារៀននោះអំពីរោគ របេង តាមរយៈដកស្រង់ពីសំណុំរឿងមានស្រាប់មកហើយ ។ បើលទ្ធផលអំពីរោគ របេង នៅល្អ គឺអ្នកអាចបន្តបានភ្លាមអំពីការសុំស្ម័គ្រជួយនៅតាមសាលារៀននោះ ។ **បួន ឆ្នាំ ម្តង គឺតំរូវឲ្យមានការបំពេញក្រដាសដាក់ពាក្យជាថ្មី ។**
2. **<u>បើអ្នកសុំផ្លាស់មកពីសាលារៀនផ្សេង</u> គឺអ្នកត្រូវបំពេញក្រដាសដាក់ពាក្យថ្មី** ។ បន្ទាប់ទៅ នាយយកសាលានឹងចុះហត្ថលេខាទទួលស្គាល់ ហើយអ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀន នឹងផ្ញើក្រដាសដាក់ពាក្យពីអ្នកទៅកាន់ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឱស្រ្ទីគ ។ បើលទ្ធផលអំពីរោគ របេង នៅល្អ គឺវាមិនចាំបាច់រាប់បញ្ចូលទេ ។ បន្ទាប់ពីបានរត់ការក្រដាសដាក់ពាក្យពីអ្នកហើយ គឺក្រដាសបង្ហាញការទទួលយល់ព្រម និង ប័ណ្ណ VIPS ID នឹងផ្ញើត្រឡប់ទៅវិញ ។ **ប័ណ្ណ VIPS ID មកពីសាលារៀនមុន គឺមិនអាចប្រើបានទេ នៅពេលផ្លាស់មកសុំស្ម័គ្រជួយនៅតាមសាលារៀនថ្មី ។**

**<u>បើលទ្ធផលអំពីរោគ របេង បានទទួលហួស ថ្ងៃ/ខែ ផុតទៅ (ធ្វើ តែស្ត ស្បែក រយៈពេល បួន ឆ្នាំ ម្តង សំរាប់រោគ របេង – TB)</u>**

**ចាំបាច់ គឺត្រូវបំពេញក្រដាសដាក់ពាក្យថ្មី ។** ការបញ្ជាក់អំពីរោគ របេង គឺត្រូវបង្ហាញ ថ្ងៃ/ខែ ធ្វើ តែស្ត ស្បែក ថ្ងៃ/ខែ អាន តែស្ត ស្បែក (ចន្លោះពេល 48-72 ម៉ោង) លទ្ធផលពីការធ្វើ តែស្ត ស្បែក និង ឈ្មោះមន្ទីរពេទ្យ ។ សំរាប់សំនួរអំពី X-ray គឺសូមទាក់ទងតាមលេខទូរស័ព្ទ (562) 997-8307 ។

**<u>អាសយដ្ឋានផ្ទះ ដែលបង្ហាញនៅលើប័ណ្ណ ID គឺត្រូវមានភាពដូចគ្នាជាមួយអាសយដ្ឋាន ដែលបង្ហាញនៅលើក្រដាសដាក់ពាក្យ ។</u>** បើអ្នកបានផ្លាស់កន្លែងរស់នៅ គឺសូមបង្ហាញភស្តុតាងអំពីអាសយដ្ឋានថ្មី ។ **រូបថតបង្ហាញនៅលើប័ណ្ណ ID ត្រូវបង្ហាញ មុខ យ៉ាងច្បាស់ ។**

***ពេលវេលាសំរាប់រត់ការក្រដាសដាក់ពាក្យ VIPS គឺនឹងចំណាយប្រើប្រហែល ពីរ សប្តាហ៍ ឬ លើស ។ សូមអ្នកគិតគូរបំពេញក្រដាសដាក់ពាក្យ VIPS ឲ្យបានត្រឹមត្រូវ និង ចុះហត្ថលេខានៅពីលើផង ដើម្បីជៀសវាងការពន្យារពេល ។ សូមអរគុណចំពោះការយកចិត្តទុកដាក់ ។**

*សូមបញ្ជាក់ថា បើមានការបង្ហាញ **ទោសកំហុស នៅលើក្រដាសដាក់ពាក្យ គឺក្រដាសមកពីតុលាការត្រូវតែមានគឺបភ្ជាប់មកជាមួយផង** និង ត្រូវការពេលវេលាយូរបន្តិចសំរាប់ធ្វើការតាមដាន ។ សំរាប់សំនួរផ្សេងៗ គឺសូមទាក់ទងអ្នកស្រី: Sharon Lazo-Nakamoto, ជាអ្នកគ្រប់គ្រងកម្មវិធី VIPS នៃក្រសួងអប់រំ ឱស្រ្ទីគ តាមលេខទូរស័ព្ទ … (562) 997-8307 ។

Revised: 08-19-17